ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...........................សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

# សម្រេច

## ប្រការ១.. គោលបំណង

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដែលស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសពន្ធ ដូចមានចែងក្នុងមាត្រា ១១៧ នៃច្បាប់ស្តីពីសារពើពន្ធ។

## ប្រការ២.. វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសពន្ធក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ ដោយផ្អែកលើមូលដ្ឋាននៃការភាន់ច្រឡំ ឬការភ្លាំងភ្លាត់ដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក បានធ្វើនៅក្នុងលិខិតប្រកាសពន្ធពីមុន។

## ប្រការ៣.. ការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដែលស្នើសុំកែតម្រូវដោយស្ម័គ្រចិត្តនូវកំហុសអចេតនាក្នុងការកត់ត្រាបញ្ជិកាគណនេយ្យ និងការប្រកាសបង់ពន្ធ ដែលបណ្តាលមកពីការយល់ដឹងអំពីកាតព្វកិច្ចសារពើពន្ធនៅមានកម្រិត ការធ្វេសប្រហែស ការភាន់ច្រឡំឬការភ្លាំងភ្លាត់ ត្រូវទទួលបានការលើកទឹកចិត្តដូចខាងក្រោម÷

### ១. ការកែតម្រូវមុនពេលមានការចុះធ្វើសវនកម្មពន្ធដារ

ចំពោះការិយបរិច្ឆេទ ដែលមិនទាន់ទទួលរងការចុះធ្វើសវនកម្មពន្ធដារ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ដែលស្ម័គ្រចិត្តចូលខ្លួនមកកែតម្រូវបញ្ជីគណនេយ្យ លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធដែលបានបង់ខ្វះឡើងវិញ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកត្រូវទទួលរងពន្ធបន្ថែមចំនួន ១០% និងទទួលបានការអនុគ្រោះបន្ថយការប្រាក់យឺតយ៉ាវ ដូចខាងក្រោម÷

ក. អនុគ្រោះបន្ថយចំនួន ៥០% ចំពោះការប្រាក់យឺតយ៉ាវ ក្នុងករណីដែលការកែតម្រូវនេះធ្វើឡើងក្នុងអំឡុងពេលមិនលើសពី ០៦ ខែ ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ

ខ. អនុគ្រោះបន្ថយចំនួន ២០% ចំពោះការប្រាក់យឺតយ៉ាវ ក្នុងករណីដែលការកែតម្រូវនេះធ្វើឡើងលើសពី ០៦ ខែ ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសពន្ធ។

### ២. ការកែតម្រូវក្នុងអំឡុងពេលទទួលរងការចុះធ្វើសវនកម្មពន្ធដារ

ប្រសិនបើអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកធ្វើការកែតម្រូវលិខិតប្រកាសពន្ធ នៅក្នុងអំឡុងពេលសវនកម្មគិតចាប់ពីពេលបានទទួលលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្ម អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកត្រូវទទួលរងពន្ធបន្ថែម ១០% និងការប្រាក់យឺតយ៉ាវ ១.៥% តាមមាត្រា១៣១ នៃច្បាប់ស្តីពីសារពើពន្ធ។ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកក៏នឹងត្រូវទទួលរងពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ តាមនីតិវិធីនិងលទ្ធផលនៃការធ្វើសវនកម្មពន្ធដារតាមមាត្រា១៣០, ១៣១, ១៣២ និង មាត្រា១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។ ក្នុងករណីនេះ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវដែលបានបង់រួច មិនអាចកាត់កងជាមួយនឹងពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ដែលជាលទ្ធផលនៃការធ្វើសវនកម្មឡើយ វៀរលែងតែអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកនោះត្រូវបានទទួលរងការធ្វើសវនកម្មលើកទី១ប៉ុណ្ណោះ។

នីតិវិធីនៃការកែតម្រូវលិខិតប្រកាសពន្ធ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ៤.  ការអនុវត្ត**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ